# សាររំលឹកឃាដករស៊ីឈ្នួល !!

- បានដាក់ប្រកាស ដោយ ដើមត្នោត មួយ ខែ មេសា 26, 2009 វេលា 5:50pm ក្នុង ទូទៅ
- ផ្ញើសារ  បន្ថែម ជាមិត្តភក្តិ  មើលការពិភាក្សា

សេរីភាពបញ្ចេញមតិ ជាសេរីភាពមូលដ្ឋាន ក្នុងចំណោមសេរីភាពមូលដ្ឋាន ដទៃ (មើល ១), មើល ២ ត្រូវតែមានសំរាប់មនុស្សគ្រប់រូប លើកលែងក្នុងរបបកុំមុយនីស្តផ្តាច់ការ (ប្រទេសយួន, ប្រទេសលាវ, ប្រទេសគុយបា, ប្រទេសខរៀខាងជើង, ប្រទេសចិន, ...) ឬក្នុងរបបយោធាផ្តាច់ការ (ប្រទេសភូមា, ...) ឬ ក្នុងរបបផ្តាច់ការដទៃ (ប្រទេសអ៊ីរ៉ាណ, ពួកប្រទេសនៅទ្វីបអាហ្វ្រិក, ...) ឬ នៅប្រទេសខ្មែរ ដែលលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស តែសំបកក្រៅ ឯធាតុពិតជាអំពើផ្តាច់ការ អំណាចក្នុងកណ្តាប់ដៃតែមនុស្សម្នាក់ (ក្នុងកណ្តាប់ដៃហ៊ុន សែន ដូចដែលលោកយ៉ាស ហ្គាយ, បេសកជនពិសេស អង្គការសហប្រជាជាតិ និយាយមិនខុសមែន)។

ខ្មែររាល់ថ្ងៃ សំគាល់ថា ឃាដករស៊ីឈ្នួល បានប្រើប្រាស់ក្រមអក្សរខ្មែរយូនីកូដ-នីដាសរសេរបានច្រើនមែន ប៉ុន្តែពាក្យសំដីរិះគន់ អំបាល់មាននោះ មិនគួរប្រើប្រាស់ ទៅលើកូនខ្មែរ លើបណ្តាញសង្គម ឬ លើអិនរើណែត ដែលគេម្នាក់ៗ បាន/កំពុងខិតខំ សរសេរបញ្ចេញវិចារ អភិវឌ្ឍក្រមអក្សខ្មែរ លើអិនរើណែត ព្រមទាំងវិភាគគ្រប់បញ្ហា ក្នុងនោះមានបញ្ហានិយាយស្តីបែបព្រៃ អា ម៉ឹង ហ្អែង ... របស់ហ៊ុន សែនជាដើម ដែលទាំងអ្នកហៃអើហ៊ុន សែនគ្មានពេញចិត្ត សំដីបែបព្រៃទាំងនោះដែរ។

ទោះយ៉ាងណា ឃាដករស៊ីឈ្នួល កំពុងជានិស្សិតខ្មែរ រៀនសូត្រនៅប្រទេសបែលហ្សិក យ៉ាងហោចណាស់ ក៏បានជ្រួតជ្រាបអរិយធម៌ ប្រទេសជឿនលឿន ដែលគេគ្មានប្រើប្រាស់សំដី បែបគ្រាន់បើ តែជាមួយអ្នកមិនតបត។

បើឃាដករស៊ីឈ្នួល ពិតជាមានទេព្យកោសល្យរិះគន់មែន, ឃាដករស៊ីឈ្នួល គួរតែ ៖
- ប្រើប្រាស់ ពាក្យសំដីរិះគន់ទាំងនោះ រិះគន់អំពើផ្តាច់ការគ្រាន់បើជាមួយខ្មែរដូចគ្នា របស់ហ៊ុន សែន ដែលបច្ចុប្បន្នហ៊ុន សែនកំពុងក្អេងក្អាង មើលថោកគ្រប់ស្រីខ្មែរ (ករណីអ្នកស្រីតំណាងរាស្ត្រ មួង សុខហួរ ) នោះ។
- ប្រើប្រាស់ ពាក្យសំដីរិះគន់ទាំងនោះ រិះគន់ រដ្ឋាភិបាលខ្មែរ ដែលអនុញ្ញាតិលំហូរពួកយួន

អន្តោប្រវេស រស់នៅពេញប្រទេសខ្មែរ
- ប្រើប្រាស់ពាក្យសំដីរិះគន់ទាំងនោះ រិះគន់ប្រទេសយួន ដែលកំពុងកៀបសង្កត់ខ្មែរកម្ពុជាក្រោម នោះ

បើបានដូច្នោះមែន, នោះនឹងប្រាកដជាត្រូវបានទទួលការសរសើរ ពីគ្រប់កូនខ្មែរ !!!
ផ្ទុយទៅវិញ បើក្អេងក្អាង តែជាមួយអ្នកគេមិនត ដូចករណីហ៊ុន សែនធ្លាប់ក្អេងក្អាង
ច្បាស់ជាគ្មានកូនខ្មែរ ណាសរសើរទង្វើនោះទេ!!

ខ្មែររាល់ថ្ងៃ អបអរគ្រប់ការចូលរួម ពីគ្រប់សមាជិក។ ខ្មែររាល់ថ្ងៃ មិនទទួល
ពាក្យសំដីគ្មានសមហេតុផល (non-logic) ព្រមទាំងលំអក់ទំនាក់ទំនង រវាងកូនខ្មែរ
ដែលខិតខំអភិវឌ្ឍក្រមអក្សរខ្មែរយូនីកូដ នោះទេ។

ជាទីបញ្ចប់ ជឿជាក់ថា ឃាដករស៊ីឈ្នួល នឹងយល់ពីទាំងអស់អ្វី បានរៀបរាប់ខាងលើ,
កែប្រែសមរម្យឡើងវិញ អត្តបទរបស់ខ្លួន និងបង្វែរទិសរិះគន់ទង្វើមិនគប្បី
របស់រដ្ឋាភិបាលខ្មែរ និង ទង្វើរបស់យួន ដែលកៀបសង្កត់ សេរីភាពបញ្ចេញមតិ
របស់ខ្មែរកម្ពុជាក្រោម។ ការបង្វែរទិសរិះគន់បែបនោះ នឹងជាទង្វើ ពេញដោយគំនិត
អភិវឌ្ឍប្រទេសខ្មែរ ពិតប្រាកដ។

បញ្ជាក់ ៖
- ឃាដករស៊ីឈ្នួល ត្រូវតែបញ្ឈប់ទង្វើ ជាពាក្យសំដី ប៉ះពាល់អារម្មណ៍សមាជិកដទៃ
លើបណ្តាញសង្គម
- សមាជិក លើបណ្តាញសង្គម គ្មានកោតក្រែង ទង្វើបែបនោះទេ ប៉ុន្តែជាទង្វើរមខាន ពួកគេ
- ក្រុមអ្នកអភិបាល គ្មានញញើតដកចេញ សមាជិកភាព របស់អ្នកដែលរំខានជានិច្ចកាល
សមាជិកដទៃ លើបណ្តាញសង្គម ទេ

# សារតបទៅដើមត្នោតមួយដោយឃាតករស៊ីឈ្នួល

សួស្តីលោក ឈរ ណារ៉ា ហៅដើមត្នោតមួយ !

ឃាតករស៊ីឈ្នួលខ្ញុំសុំអរគុណជាអនេកចំពោះសាររបស់លោកដែលបានដាក់បង្ហាញព្រមានជាសាធារណៈដល់ឃាតករស៊ីឈ្នួលខ្ញុំនៅក្នុងគេហទំព័រខ្មែររាល់ថ្ងៃ។សុំបញ្ជាក់ថាឃាតករស៊ីឈ្នួលខ្ញុំមិនមែនជានិស្សិតរៀននៅប៊ែលហ្ស៊ិកដូច លោកបានបញ្ជាក់នោះទេ។ ខ្ញុំសុំអរគុណដល់លោក ឈរ ណារ៉ា ហៅដើមត្នោតមួយដល់ការផ្តល់នូវកិត្តិយសដល់ខ្ញុំដោយ ប្រៀបប្រដូចឃាតករស៊ីឈ្នួលខ្ញុំទៅនឹងបញ្ញវ័ន្តជាន់ខ្ពស់ម្នាក់។

ឃាតករស៊ីឈ្នួលខ្ញុំធ្លាប់បានប្រកាសប្រាប់រួចមកហើយថាឃាតករស៊ីឈ្នួលខ្ញុំមិនចូលមកក្នុងបណ្តាញសង្គមខ្មែររាល់ថ្ងៃនេះដើម្បីធ្វើសង្គ្រាម ឬ បង្កជំលោះឈ្លោះជាមួយសមាជិកណាម្នាក់ឡើយ។ ឃាតករស៊ីឈ្នួលខ្ញុំគោរពនូវសិទ្ធិបញ្ចេញមតិ សិទ្ធិសេរីភាពរបស់មនុស្សគ្រប់រូប (ប៉ុន្តែសុំកុំប៉ះពាល់ដល់គ្រូអាចារ្យ ឪពុកម្តាយរបស់ឃាតករស៊ីឈ្នួលឲ្យសោះ ! )។ ខ្ញុំនិងមិនទុកមុខទុកមាត់ដល់មនុស្សណាម្នាក់ដែលហ៊ាន មើលងាយរិះគន់ តិះដៀលដល់គ្រូឧបធ្យាយឪពុកឬម្តាយរបស់ឃាតករស៊ីឈ្នួលជាដាច់ខាត។

ទាក់ទងទៅនឹងរឿងនយាបាយក្នុងប្រទេស ឃាតករស៊ីឈ្នួលខ្ញុំសុំជំរាបប្រាប់លោកថាពេជ្ឈឃាតមុខស្រស់ខ្ញុំមិនចាប់អារម្មណ៍ក្នុងរឿងវិវាទនយោបាយ រិះគន់មេដឹកនាំ មើលងាយដល់ប្រទេសជាតិខ្លួនឯងជាដាច់ ខាតបញ្ហានយោបាយវាជារឿងដែលមនុស្សមួយក្រុមនៅក្នុងប្រទេសពាក់ស្បែកមុខដាក់គ្នា ចែករំលែក អំណាចបុណ្យសក្តិ និងលាភសក្ការះដល់គ្នាទៅវិញទៅមក ដោយប្រើប្រាស់ប្រជាជនស្លូតត្រង់ជាឈ្នាន់។ សង្គមណាក៏ដូចជាសង្គមណា សម័យណាក៏ដូចជាសម័យណាដែរ ការបោកប្រាស់ កុហក របស់អ្នកនយោ បាយមកលើប្រជារាស្ត្រស្លូតត្រង់ត្រូវបានគេប្រទះឃើញជារៀងរាល់ថ្ងៃ។ សួរថាតើអ្នកណាជាអ្នករងគ្រោះបន្ទាប់ពីអ្នកនយោបាយពាក់ស្បែកមុខដាក់គ្នា ឈ្លោះគ្នាចប់? ប្រជារាស្ត្រស្លូតត្រង់តើមែនឬមិនមែន?

**បញ្ហាលោក ហ៊ុន សែន ខ្ញុំសុំបំភ្លឺលោកក្នុងរឿងនេះ**

លោកជាអ្នកស្រែកចោទលោក ហ៊ុន សែន ថាជាមនុស្សពាល ព្រៃផ្សៃ គ្មានចំណេះដឹង ហើយលោកថា  សំដីសំដៅរបស់លោក ហ៊ុន សែនគឺអាចបញ្ជាក់ច្បាស់ណាស់នូវមាយាទ និងចំណេះដឹងរបស់គាត់។ ខ្ញុំសុំសួរលោកឈរ ណារ៉ា ដែលជាបញ្ញាវ័ន្តខ្មែរជាន់ខ្ពស់មួយរូបទៅវិញលមើលថា បើលោកចោទគេថាឆ្កួតតើយើងដែលជាមនុស្សត្រឹមត្រូវ ខួរក្បាលប្រក្រតី ទៅប្រឡូកប្រឡាក់ជាមួយមនុស្សបែបនេះបានផល ប្រយោជន៍

ស្អីខ្លះទៅ? មនុស្សម្នាគេនឹងចោទយើងថាយើងនេះវាឆ្កួតដូចលោក ហ៊ុន សែន ដែរ ! តើខ្ញុំនិយាយនេះត្រូវឬមិនត្រូវ?សុំលោកឆ្លើយទៅមើល ! លោកស្រែកដៀលគេ ចោទគេថាឆ្កួត ព្រៃផ្សៃ ឃោរឃៅ ផ្តាច់ការ ត្រង់នេះលោកចូលលក្ខណៈបរិហារកេរ្តិ៍គេហើយណាលោក ! បើសិនជាគេចង់ប្តឹងនោះលោក ឈរ ណារ៉ា ហៅដើមត្នោតមួយ រត់អត់រួចខ្លួនទេ ត្រូវដឹងទៅ ! ករណីនេះមានច្រើនរួចមកហើយ គឺលោកសម រង្ស៊ីដែលបានចោទប្រកាន់លោក លោក ហោ ណាំហុង ថាជាប្រធានគុកបឹងត្របែកនៅសម័យប៉ុលពត ដោយគ្មានមូលដ្ឋានច្បាស់លាស់។ មានអីដល់គេប្តឹងតាំងឡាំប៉ាស្រែកថាតុលាការនៅស្រុកខ្មែរគ្មានយុត្តិធម៌ទេ គឺនៅក្រោមអំណាចរបស់គណបក្សប្រជាជន កាន់អំណាច។ ចង់បានយុត្តិធម៌ឬ? លោក ហោ ណាំហុង បានឡើងទៅប្តឹងដល់តុលាការស្រុកបារាំងទៅទៀត ព្រោះលោកសម រង្ស៊ីមានសញ្ជាតិបារាំង។ ឃើញហើយថាលទ្ធផលយ៉ាងម៉េច? តុលាការស្រុកបារាំងដែលលោក សម រង្ស៊ីតែងតែអួតកោកៗថាយុត្តិធម៌នោះ កាត់ក្តីឲ្យគាត់ចាញ់យ៉ាងអាម៉ាស់ហើយតំរូវឲ្យគាត់បង់លុយសងជាជំងឺចិត្តដល់លោក ហោ ណាំហុងទៀត !

ករណីនេះតើលោកសម រង្ស៊ី និងលោក ឈរ ណារ៉ា ហ៊ានចោទប្រកាន់ថាតុលាការស្រុកបារាំងអយុត្តិធម៌ហើយស្ថិតនៅក្រោមអំណាចនយោបាយផ្តាច់ការរបស់លោក ហ៊ុន សែន និងគណបក្សប្រជាជននៅប្រទេសខ្មែរដែរឬទេ?  លោកហ៊ានចោទទេ? ឬមួយស្ងាត់មាត់ដូចគេចុក?

តាមពិតទៅលោកមានចរិតដូចលោក សម រង្ស៊ីដែរតើ ! បើសិនជាគេស្លូតមិននិយាយស្តីនោះលោកហើយនិងលោក សម រង្ស៊ីជាន់ក្បាលគេ។ ដល់ពេលដែលគេកាច ម៉ឹងម៉ាត់ ម៉ត់ចត់ លោកនិងលោក សម រង្ស៊ីស្រែកចោទប្រកាន់គេថាផ្តាច់ការ ឃោរឃៅ ! រឿងនេះសុំលោក ឈរ ណារ៉ា ទៅឆ្លុះកញ្ចក់មើលខ្លួនឯងវិញម្តងទៀតពីអត្តចរិតមិនគប្បីរបស់លោក មុននឹងលោកស្រែកថាឲ្យគេ។

ករណី លោក សម រង្ស៊ី លោក កឹម សុខា លោកស្រី មូរ សុខហួរ ជាដើម។ល។ ឃាតករស៊ីឈ្នួលខ្ញុំសុំបញ្ចេញនូវការគោរពដល់អស់លោក លោកស្រីទាំងនោះដែលក្លាហានក្នុងការប្រឆាំងនិងលោក ហ៊ុន សែនដោយពេញមុខដោយស្របច្បាប់តាមរយៈគណបក្សប្រឆាំង។ ប៉ុន្តែសុំលោកកុំភ្លេចថាគោលដៅរបស់ពួកគេទាំងនោះគឺធ្វើឡើងដើម្បីសំលឹងយកផលប្រយោជន៍ពីរាស្ត្រខ្មែរ ល្ងង់ខ្លៅ ស្លូតត្រង់ ដើម្បីជាឈ្នាន់ឈាន ទៅរកការកាន់អំណាចនៅក្រោយពីការបោះឆ្នោត (បើមិនបានផលចំណេញ គេមិនធ្វើទេ !!! រឿងនេះ មនុស្សណាក៏ដូចជាមនុស្សណាដែរគឺតែងតែបានគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនជាធំ)។ រឿងនេះដែរលោកត្រូវគិតថាបើសិនជាគ្មានប្រយោជន៍ដល់គាត់ ស្មានថាតើលោកហ៊ុន សែន នោះទុកមនុស្សណាដែលប្រឆាំងនឹងគាត់ឲ្យមាននៅក្នុងស្រុកខ្មែរដែរទេ? លោក ឈរ ណារ៉ា បាននិយាយច្បាស់ណាស់ ថាលោកហ៊ុន សែន មានចរិតព្រៃផ្សៃ កាចសាហាវ ហើយគាត់មិនដែលទុកមនុស្សណាម្នាក់ដែលហ៊ានចេញមុខប្រឆាំងនឹងគាត់ឲ្យនៅរស់នៅក្នុងស្រុកខ្មែរនោះទេ។ តើគាត់អនុញ្ញាតិឲ្យបង្កើតនិងទុកបក្សប្រឆាំងដើម្បីធ្វើអី? ចំលើយគឺដើម្បីទទួលបាននូវលុយជំនួយពីសហគមន៍អន្តរជាតិ ដើម្បីឲ្យសហគមន៍អន្តរជាតិជឿថាស្រុកខ្មែរមានការគោរពនូវលទ្ធិប្រជាធិបតេយ្យ តាមរយៈមានគណបក្សប្រឆាំង។

លោក ឈរ ណារ៉ា ប្រហែលជាបានឮពាក្យដំណាលគេធ្លាប់បាននិយាយរួចមកហើយពីរឿងអ្នកនយោបាយ គឺ **មួយណាក៏ដូចមួយណាដែរ** (ក្នុងភាសាអង់គ្លេសគេនិយាយថា *Politicians are all the same shits but different faces*)។ រឿងនយោបាយក្នុងស្រុកនោះ ឃាតករស៊ីឈ្នួលខ្ញុំមិនត្រឹមតែ វិភាគ ឬ ហារមាត់ស្រែកដូចមនុស្សឆ្កួតស្រែករឡេរឡូតាមថ្នល់នោះទេ ! ឃាតករស៊ីឈ្នួលខ្ញុំធ្លាប់ហាក់ចូលប្រឡូកយ៉ាងក្រាស់ក្រែលជាច្រើនឆ្នាំ ប៉ុន្តែដោយ ឃើញថាវាគ្មានប្រយោជន៍នោះ ទើបឃាតករស៊ីឈ្នួលខ្ញុំដើរចាកចេញឆ្ងាយពីរឿងនេះ (សូមបញ្ជាក់ថាឃាតករស៊ីឈ្នួលខ្ញុំមិនចូលចិត្តនិយាយ ឬ ស្រែក ហៃអ៊ើ តាមគេនោះទេ គឺឃាតករស៊ីឈ្នួលខ្ញុំចូលចិត្ត ធ្វើតែម្តង ហើយនេះជាចរិតផ្ទាល់ខ្លួនរបស់ពេជ្ឃឃាតមុខស្រស់ខ្ញុំ)។ លោកត្រូវចាំថា**នយោបាយគឺជាការប្រើល្បិច អ្នកខ្លាំងឈ្នះអ្នកខ្សោយ ! ហើយគ្មានទេយុត្តិធម៌សំរាប់សង្គមអ្នកនយោបាយ ! សង្គមនយោបាយជាសង្គមពាល ជាសង្គមងងឹត !** លោកធ្លាប់បានឃើញបានដឹងរួចមកហើយថាវាសនាចុងក្រោយរបស់អ្នកនយោបាយនៅស្រុកខ្មែរគឺ ស្លាប់ចូលគុក ព្រាត់ប្រាសប្រពន្ធកូនឬត្រូវរត់ចោលស្រុកជាដើម។ ករណីលោក ហ៊ុន សែន លោក សម រង្ស៊ី លោក កឹម សុខា ជាដើម។ ខ្ញុំបានប្រមើលមើលរួចទៅហើយ ថាពួកអស់លោកទាំងនោះគ្មានសមត្ថភាពក្នុងការដឹកនាំប្រទេសខ្មែរទេ។ លោក សម រង្ស៊ី លោក កឹម សុខា អាចគ្រាន់តែធ្វើជាប្រទីបជាផ្លូវដឹកនាំសង្គមស្រុកខ្មែរឲ្យស្គាល់ប្រជាធិបតេយ្យការបញ្ចេញមតិ ការគោរពសិទ្ធិមនុស្សតែប៉ុណ្ណោះ ប៉ុន្តែពួកលោកទាំងនោះត្រូវការមានបទពិសោធន៍ច្រើនបន្តទៀតដើម្បីធ្វើការ ដឹកនាំប្រទេស។

**ហេតុដូចនេះហើយបានជាឃាតករស៊ីឈ្នួលខ្ញុំ គ្មានជំនឿចិត្តទៅលើអ្នកនយោបាយទាល់តែសោះ !**

## ករណីអន្តោប្រវេស្តន៍

តើលោក ឈរ ណារ៉ា អាចបញ្ជាក់ប្រាប់ឃាតករស៊ីឈ្នួលខ្ញុំបានដែរទេថា តើនៅក្នុងប្រទេសណាមួយនៅលើលោកយើងនេះដែលគ្មានបញ្ហារឿងអន្តោប្រវេស្តន៍? សេរីភាពដើរហើររបស់មនុស្សគ្មានព្រំដែនទេលោក ! មនុស្សទេដែលជាអ្នកកំណត់ព្រំដែន មិនមែនពិភពលោកកំនត់ព្រំដែនមនុស្សនោះទេ ! រឿង អន្តោប្រវេស្តន៍នោះវិញវាមិនមែនទើបតែកើតឡើងនៅក្នុងសម័យថ្មីៗនេះទេ គឺវាកើតមានឡើងរាប់រយ លានឆ្នាំរួចមកហើយតាំងពីសម័យអូស្រ្តាឡូពីតែក អូម៉ូអេរិកទីសណោអង់ឌែរតាល់។ លោកឃើញហើយថាតើពពួកមនុស្សបុរប្រវត្តិប្រវត្តិសាស្រ្តទាំងនោះធ្វើដំណើរដល់ណាខ្លះ? ស្ទើរតែពាសពេញពិភពលោក !រឿងអន្តោប្រវេស្តន៍យួនចូលក្នុងស្រុកខ្មែរ លោកស្មានតែឃាតករស៊ីឈ្នួលខ្ញុំមិនឈឺក្បាល ធុញទ្រាន់នឹង ពួកអស់នោះឬ?តើឲ្យខ្ញុំធ្វើយ៉ាងម៉េច? ទៅឃាត់ឃាំងសិទ្ធិសេរីភាពដើរហើររបស់គេ? ខ្ញុំគ្មានលទ្ធភាពធ្វើ បានទេរឿងនេះនោះ។ រឿងនេះ **ខ្ញុំហាក់ដូចគ្មានចិត្តចង្អៀតចង្អល់ទេក្នុងការធ្វើអន្តោប្រវេស្តន៍មករស់នៅ ក្នុងប្រទេសយើង ប៉ុន្តែសុំឲ្យគេទាំងអស់នោះគោរពច្បាប់របស់ប្រទេសខ្មែរយើងទៅវាចប់បាត់ហើយ។**

ឃាតករស៊ីឈ្នួលខ្ញុំបើកចិត្តទូលាយដល់រឿងអន្តោប្រវេស្តន៍នេះ ព្រោះចង់អ្នកណាមករស់នៅស្រុកខ្មែរ ក៏បាន

ដែរឲ្យតែពួកគេគោរពច្បាប់ ប្រពៃណី វប្បធម៌ របស់ប្រទេសខ្មែរទៅចប់ហើយ។

ខ្ញុំធ្លាប់បានឮខ្មែររស់នៅបរទេសជាពិសេសខ្មែរនៅស្រុកបារាំង ស្រុកអាមេរិក ជាដើមនិយាយរិះគន់រឿងអន្តោប្រវេសន្ត៍នៅក្នុងស្រុកខ្មែរនេះ ប៉ុន្តែតើពួកគេទាំងនោះមានដែល គិតដែរទេថាតើមានប្រជាជនខ្មែរប៉ុន្មានលាននាក់ដែលបានធ្វើអន្តោប្រវេសន្ត៍ទៅរស់នៅប្រទេសជឿន លឿនដ៏ទៃ ដូចជា អាមេរិក បារាំង កាណាដា អូស្ត្រាលី ញូហ្សេលែន? ពួកអស់លោកពូកែបានតែរិះគន់ទាំងនោះ ភ្លេចខ្លួនហើយថាខ្លួនឯងហើយប្រជាជនខ្លួនឯងសញ្ជាតិខ្លួនឯងទៅរស់នៅលើទឹកដីគេ ប្រទេសរបស់ជនជាតិ ដ៏ទៃទៀត។ ស្មានតែជនជាតិដើមរបស់គេមិនធុញទ្រាន់ឬក្នុងបញ្ហានេះ? ពួកសាសន៍បរទេសនោះគេធុញទ្រាន់ណាស់តាមខ្ញុំ ដឹង ប៉ុន្តែពួកគេមិនដឹងជាធ្វើយ៉ាងម៉េច? ពួកគេមិនអាចឃាត់ឃាំងសិទ្ធិសេរីភាពដើរហើររបស់មនុស្ស ដ៏ទៃបានទេដូច្នេះពួកគេត្រូវបើកចិត្តទូលាយទៅវិញ ធ្វើមិនដឹងមិនឮ មិនចាប់អារម្មណ៍ សំខាន់ឲ្យតែ ប្រជាជនខ្មែរយើងដែលទៅរស់នៅលើទឹកដីរបស់ពួកគេគោរពច្បាប់ស្រុកគេ គោរពប្រពៃណី ទំនៀមទំលាប់ វប្បធម៌របស់គេ។ សាកមិនហ៊ានគោរពច្បាប់ស្រុកគេ ធ្វើអំពើពាលាអាវ៉ាសែ បង្កទុក្ខលំបាក ដល់សង្គមរបស់គេលមើល បើមិនគេដកសញ្ជាតិចាប់បញ្ជូនត្រលប់មកប្រទេសដើមវិញខ្ញុំហ៊ានភ្នាល់ (ករណីនេះមានច្រើនរួចមកហើយប៉ុន្មានឆ្នាំកន្លងថ្មីៗទៅនេះ ហើយឃាតករស៊ីឈ្នួលខ្ញុំបានធ្វើការងារ ផ្ទាល់ជាមួយនឹងបងប្អូនខ្មែរអត់សណ្តាប់ធ្នាប់ដែលត្រូវបានគេនិរទេសខ្លួនត្រលប់មកស្រុកខ្មែរវិញទៀតផង)។ **ទឹកត្រជាក់ត្រីកុំ !** កន្លែងណាដែលគេគឹតថាអាចរស់នៅស្រួលគឺគេទៅរស់នៅហើយ រឿងនេះមិនបាច់ឆ្ងល់ទេ !

**ខ្ញុំគិតថាខ្មែររស់នៅបរទេសដែលមានចិត្តគំនិតចង្អៀតចង្អល់ ប្រកាន់ពូជសាសន៍បែបនោះ បានតែស្រែកទេ ប៉ុន្តែគ្មានបានឃើញធ្វើការអ៊ីធំដុំជាការតបស្នងសងគុណដល់ប្រទេសជាតិឯងទេ ! បើចិត្តសៀងបោះសញ្ជាតិបរទេសចោលដូចខ្ញុំមក ហើយមករស់នៅស្រុកខ្មែរ ជួយអភិវឌ្ឍន៍សង្គមខ្មែរឲ្យបានរីកចំរើន ទៅតាមលទ្ធភាពដែលខ្លួនមានទៅមើល ! តើហ៊ានទេ? ចិត្តសៀងអត់? បើចិត្តសៀង ធ្វើដូចខ្ញុំ ធ្វើដូចលោកបណ្ឌិតឡៅ ម៉ុងហៃ លោក ឆាំង យុគ លោកស្រី ពុង ឈីវហ្គេក លោកស្រី មូរ សុខហួរ ទៅមើល កុំចេះតែស្រែកនោះ !**

**ខ្ញុំគិតថាពួកខ្មែរចោលម្សៀតខ្លះដែលរស់នៅបរទេសទាំងនោះកំសាកខ្លាំងណាស់មិនហ៊ានបោះសញ្ជាតិបរទេសចោលហើយមករស់នៅជួយស្រុកខ្មែរទេ ! សញ្ជាតិបរទេសវាថ្លៃថ្នូរខ្លាំងណាស់ ឯសញ្ជាតិខ្មែរឯងវិញវាថោកទាបអបលក្ខណ៍ណាស់ ! បានទៅរស់នៅបរទេសប៉ុណ្ណឹងគិតថាអស្ចារ្យខ្លាំងណាស់ថ្លើមធំហ៊ានដៀលមើលងាយប្រទេសខ្មែរដែលជាប្រទេសកំណើតរបស់ខ្លួនឯង។ ឬមួយគ្មានចំណេះទេក្នុងការមកធ្វើការងារជួយនៅស្រុកខ្មែរតាមសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលទេបានជាខំស្រែកជំទាល មើលងាយប្រទេសខ្លួនពីបរទេសយ៉ាងនេះ?ខ្ញុំស្អប់មនុស្សប្រភេទនេះខ្លាំងណាស់ !**

ខ្ញុំសុំប្រាប់លោកតាមត្រង់ទៅចុះថាកាលដែលខ្ញុំនៅរស់នៅឯបរទេសនោះ ខ្ញុំនេះមិនមែនទៅធ្វើការងារលើសែងជាកម្មករនៅរោងចក្រដូចខ្មែរសំគិះៗដែលចូលចិត្តមើលងាយប្រទេសជាតិរបស់ខ្លួនទាំងនោះទេ ! ខ្ញុំ

ធ្វើការនៅកន្លែងមានមុខមានមាត់ អង្គុយក្នុងការិយាល័យធ្វើការត្រឹមត្រូវ ទៅតាមចំណេះដែលខ្ញុំខិតខំប្រឹងរៀនសូត្រ។ តើលោក ឈរ ណារ៉ា មានឆ្ងល់ដែរទេថាហេតុអីបានជាខ្ញុំសំរេចចិត្តបោះបង់សញ្ជាតិ និងជីវិតហ៊ីហាស៊ីវីល័យនៅឯបរទេស មករស់នៅត្រដាបត្រដូស ស៊ីអត់ស៊ីឃ្លាននៅស្រុកខ្មែរទៅវិញ? លោកឆ្លើយទៅមើល !

## ករណីយួនគ្រប់គ្រងប្រទេសខ្មែរ

លោក ឈរ ណារ៉ា គួរតែសិក្សារឿងនេះឲ្យបានច្បាស់បន្តិច។ រឿងនេះជារឿងនយោបាយ ជារឿងប្រទេសជាតិជារឿងជាតិខ្មែរទាំងមូល។ **ធម្មតាទេច្បាប់ធម្មជាតិអ្នកខ្លាំងឈ្នះអ្នកទន់ខ្សោយ !សត្វធំស៊ីសត្វ តូច ! បើសិនជាខ្មែរយើងខ្លាំងនោះមិនមែនយួនមកត្រួតត្រាបាននោះទេលោកត្រូវចាំ ! យើងត្រូវទទួលស្គាល់នូវការពិតថាយើងនេះខ្សោយទើបគេមកត្រួតត្រាយើងបាន។តើយើងត្រូវធ្វើដូចម្តេចដើម្បីរំដោះខ្លួនយើងពីនឹមត្រួតត្រានេះបាន ? (ខ្ញុំទុកសំនួរនេះដល់លោកឆ្លើយខ្លួនឯងចុះ)**

សុំលោកក្រលេកមើលករណីចក្រភពរុស្សីលេបត្របាក់ប្រទេស បេឡារូស អ៊ុយក្រែន ឡាត់វីយ៉ា អាហ្សែ រប៉ៃហ្សង់និងប្រទេសច្រើនទៀតស្ទើរតែពេញមួយអឺរ៉ុបខាងកើត។ សួរថាតើនោះបណ្តាលមកពីបញ្ហាអី? កាលពីសម័យខ្មែររុងរឿងខ្លាំង ចក្រភពខ្មែរវាយយកប្រទេសចាមមកត្រួតត្រា វាយយកមន ពន្លាតទឹកដីដល់ម៉ាឡេស៊ីតើនោះបណ្តាលមកពីកត្តាអ្វី? ចុះនៅពេលដែលខ្មែរចុះអន់ខ្សោយ បាត់ទឹកដី បរទេសឈ្លានពាន នោះតើវាបណ្តាលមកពីកត្តាអ្វីដែរ (លោកឆ្លើយទៅមើល?)

## បញ្ហាខ្មែរ ក្រោម និង បញ្ហាខ្មែរសុរិន្ទ ដែលនៅក្រោម ការត្រួតត្រារ បស់យួន និង សៀម

ឃាតករស៊ីឈ្នួលខ្ញុំសួរថាតើមួយណាដែលមិនឈឺចាប់នឹងការបាត់បង់ទឹកដីរបស់ខ្លួនឯងនោះ? រាល់លើកដែលខ្ញុំទៅលេងនៅខេត្តកម្ពុជាក្រោម ទៅលេងនៅសុរិន្ទខ្ញុំស្ទើរតែស្រក់ទឹកភ្នែកក្លាយជាឈាមនៅពេលដែលឃើញប្រជារាស្ត្រខ្លួនឯងលែងនិយាយភាសាខ្លួន លែងស្គាល់វប្បធម៌ខ្លួន។ខ្មែរមួយណា ដែលមិនចង់ឲ្យទឹកដីដែលយើងបាត់បង់នោះត្រលប់មកវិញ? តើត្រូវធ្វើដូចម្តេចដើម្បីទាមទារយកទឹកដី ទាំងនោះមកវិញ? ធ្វើសង្គ្រាម? ខុសហើយ ! សតវត្សរ៍នេះជាសតវត្សរ៍ដែលគេនិយាយគ្នាតាមផ្លូវច្បាប់មិនមែនលើកអាវុធបាញ់ប្រហារគ្នាតាមរបៀបពួកចោរព្រៃ ឬជា ប្រជាជាតិគ្មានអារ្យធម៌នោះទេ។ បើនិយាយ តាមផ្លូវច្បាប់ខ្មែរយើងនេះចាញ់ប្រទេសយួននិងសៀមបាត់ទៅហើយ ព្រោះមិនអាចទាមទារយកទឹកដី ទាំងនោះមកវិញបានទេត្រូវចាំ ! សន្ធិសញ្ញាអន្តរជាតិបានកំណត់ហើយថាយើងអាចទាមទារទឹកដីដែល បាត់បង់មកវិញបានក្នុងរយៈពេលក្នុងចន្លោះប្រហែលពី ៦០ ទៅ ៨០ ឆ្នាំ។ សួរថាតើខ្មែរកម្ពុជាក្រោម ខ្មែរសុរិន្ទយើង បាត់បង់នៅក្នុង

សម័យណា? បើលើកទ័ពធ្វើបដិវិត្តន៍ទៅទាមទារយកដីទាំងនោះមកវិញសួរថាតើសៀម និងយួនវាព្រមទេ? ច្បាស់ជា មិនព្រមទេ (ពួកវាខំប្រឹងលេបយកទៅដោយលំបាករឿងអីដែលពួកវាត្រូវប្រគល់មកឲ្យខ្មែរយើងវិញ ដោយងាយស្រួលនោះ ! ត្រូវគិតមើលទៅ! )។ ករណីនេះ អ្នកនយោបាយជាច្រើនបានលើកយករឿងនេះមកធ្វើជាលេសជាខែលដើម្បីទទួលបានសំលេងគាំទ្រពីប្រជាជនដោយស្រែកហារមាត់ថាពេលខ្លួនឈ្នះឆ្នោត ខ្លួននឹងទៅយកខេត្តខ្មែរដែលបាត់បង់នៅយួននៅសៀមមកវិញ (ខ្ញុំហ៊ាននិយាយថាពួកអ្នកនយោបាយទាំងនោះស្រមើស្រម័យខ្លាំងពេកហើយ ! ហើយពួកគេបោកប្រាស់បានតែប្រជាជនស្លូតត្រង់ មិនបានរៀនសូត្រខ្ពង់ខ្ពស់តែប៉ុណ្ណោះ)។

មិនបាច់ទៅទាមទារយកមកវិញទេ ព្រោះវាគ្មានឃើញផ្លូវណាឈ្នះគេសោះទាំងផ្លូវច្បាប់ទាំងផ្លូវ សង្គ្រាម ! ប្រៀបធៀបតែប្រជាជនខ្មែរនិងប្រជាជនសៀម និង យួនទៅឃើញថាខុសគ្នាប៉ុនណា ! ឬមួយក៏ចង់បញ្ជូនខ្មែរឲ្យទៅងាប់គរជើងគ្នា ដូចភ្នំតទៅទៀត? ល្មមឈប់ហើយ ! អាណិតទឹកភ្នែកប្រជារាស្រ្តខ្មែរ ផងទៅ ! កុំយកជីវិតរបស់គេទៅងាប់ទទេដោយសារតែនយោបាយអត់ប្រយោជន៍ស្រមើស្រមៃជ្រុលរបស់ខ្លួនដូច្នេះនោះ ! រក្សាតែទឹកដីដែលខ្លួនមានសព្វថ្ងៃកុំឲ្យមានការបាត់បង់តទៅមុខទៀត ទៅវាបានល្អណាស់ទៅហើយសំរាប់ប្រជាជនខ្មែរ និងប្រជាជាតិខ្មែរទាំងមូលនោះ។

ឃាតករស៊ីឈ្នួលខ្ញុំមិនប្រមើលឃើញថាមានផ្លូវដែលល្អក្នុងការយកទឹកដីខ្មែរដែលបាត់បង់ទៅនោះត្រលប់មកវិញទេ។ វាគ្មានផ្លូវទេ ! (តើលោកឈរ ណារ៉ា ហ៊ានភ្នាល់ជាមួយខ្ញុំទេក្នុងរឿងនេះ? តើអ្នកណាជាអ្នកទៅយក? ជាលោក ឈរ ណារ៉ា វីរបុសជាតិខ្មែរ វីរបុរសប្រទេសខ្មែរ? ឃាតករស៊ីឈ្នួលខ្ញុំហ៊ានភ្នាល់ដាក់អាយុជីវិត ប្រសិនណាបើទឹកដីខ្មែរដែលបានបាត់បង់ទៅនៅប្រទេសសៀម ប្រទេសយួន ត្រលប់មកដីខ្មែរវិញ ! តើលោក ឈរ ណារ៉ា ហ៊ានលេងល្បែងភ្នាល់នេះជាមួយឃាតករស៊ីឈ្នួលខ្ញុំទេ? )។ ប្រសិនបើប្រជាជននៅតំបន់នោះងើបឡើងបះបោរ ប្រកាសផ្តាច់ខ្លួន ជារដ្ឋឯករាជ្យ ឈប់រស់នៅក្រោមចំនុះប្រទេសយួន និង ប្រទេសសៀម ដោយរដ្ឋឯករាជ្យថ្មីនោះនិយាយភាសា ខ្មែរ សៀម (ខេត្តសុរិន្ទក្នុងទឹកដីសៀម) និងនិយាយភាសា ខ្មែរ យួន (តំបន់កម្ពុជាក្រោម) ក្រែងលោឃាតករស៊ីឈ្នួលខ្ញុំជឿខ្លះ។ បើឲ្យត្រលប់មកជាដីខ្មែរវិញ ឃាតករស៊ីឈ្នួលខ្ញុំមិនជឿជាដាច់ខាត ! ហើយវិធីដែលល្អដើម្បីជំរុញរដ្ឋទាំងនោះបះបោរទាមទារឯករាជ្យ គឺខ្មែរយើងនៅប្រទេសខ្មែរសព្វថ្ងៃនេះត្រូវតែខ្លាំងជាងខ្មែរដែលរស់នៅក្រោមចំនុះសៀមនិងយួន ទាំងសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្រ្ត សព្វាវុធ ការទូត និង នយោបាយ។ គេត្រូវបង្រៀនភាសាខ្មែរទៅដល់ពួកខ្មែរទាំងនោះពន្យល់និងបង្ហាត់បង្ហាញថាតើពួកគេមានឈាមជ័រមកពីណា? ធ្វើយ៉ាងណាឲ្យពួកគេស្គាល់ខ្លួនឯងច្បាស់ដល់ពេលនោះខ្មែរយើងមិនចាំបាច់ទៅលើកទ័ពវាយយកទឹកដីមកវិញទេ ច្បាស់ជាពួកគេនឹងផ្តាច់ខ្លួនងើបឡើងបះបោរប្រឆាំងនឹងសៀម យួន ដោយខ្លួនឯងដោយស្វ័យប្រវត្តិ។ ពេលនោះខ្មែរយើង និងចំណេញទាំងផ្លូវទូត ទាំងផ្លូវនយោបាយដោយស្រួល បើទោះបីជាគេចង់ចោទប្រទេសខ្មែរថាបានធ្វើ ឲ្យមានចលនាបះបោរ ផ្តាច់ខ្លួនក្នុងប្រទេសរបស់ពួកគេក៏មិនបានដែរព្រោះខ្មែរអត់មានលូកដៃចូលទៅ ក្នុងការងារនយោ

បាយប្រទេសគេទេ គឺប្រជាជនរបស់ពួកគេទេដែលងើបឡើងបះបោរ ផ្តាច់ខ្លួនដោយ ខ្លួនឯងនោះ ! មិនថាអញ្ចឹង? (រឿងនេះសូមលោក ឈរ ណារ៉ា ទៅមើលលក្ខនិត្តិកៈរបស់ប្រទេសនីមួយៗ និងច្បាប់ចូលជាសមាជិកអាស៊ានឡើងវិញទៅ ! )

ឃាតករស៊ីឈ្នួលសុំរក្សាសិទ្ធិមិនធ្វើការលូកលាន់រិះគន់ មើលងាយតិះដៀលដល់អ្នកបណ្តាអ្នកនយោបាយក្នុង ប្រទេស ក៏ដូចជាមើលងាយតិះដៀលដល់ប្រទេសជាតិរបស់ខ្លួនជាដាច់ខាត។ ពេជ្ឈឃាតមុខស្រស់ខ្ញុំសុំស្ថិត នៅអព្យាក្រិត មិនរវីរវល់ អើពើ រឿងនយោបាយ ព្រោះឃាតករស៊ីឈ្នួលខ្ញុំមិនបណ្តោយខ្លួនឲ្យធ្លាក់ជាឈ្នាន់របស់អ្នកនយោបាយណាមួយជាដាច់ខាត។ ម៉្យាងទៀតលោក ឈរណារ៉ា ក៏គ្មានសិទ្ធិអីមកបញ្ជាឃាតករស៊ីឈ្នួលខ្ញុំឲ្យធ្វើការវាយប្រហារអ្នកនយោបាយ ឬ ប្រទេសយួន ប្រទេសសៀមតាមដែលចិត្តលោកនឹកឃើញនោះទេ ! លោកជាបញ្ញាវ័ន្តខ្មែរមួយរូបដែលរៀនបានចេះដឹងខ្ពង់ខ្ពស់ប៉ុន្តែលោកហាក់ដូចជាមិនចេះគោរពសិទ្ធិមនុស្ស និងគ្មានសុជីជធម៌សោះ លោកគិតថាឃាតករស៊ីឈ្នួលខ្ញុំជាមនុស្សងាយស្រួលនឹងលោកបញ្ជាក្បាលបានដូចលោកគិតនោះឬ? សុំទោស លោកច្រលំធំហើយ ! លោករៀនបានខ្ពស់ប៉ុន្តែលោកគ្មានសុជីវធម៌បន្តិចសោះ ! លោកហារមាត់ ដៀល ស្រែកជំទាលមើលងាយថា ស្រុកខ្មែរជាស្រុកមិនគោរពសិទ្ធិមនុស្ស ប៉ុន្តែខ្លួនលោកទៅវិញទេដែលបំពានលើច្បាប់សិទ្ធិមនុស្សដោយខ្លួនឯង! លោកមិនខុសពីពាក្យចាស់គេថា គីង្គក់លក់ថ្នាំស្រែងនោះទ "។ ឃាតករស៊ីឈ្នួលខ្ញុំនៅមិនទាន់យល់ថាតើសកលវិទ្យាល័យមួយណាតើសកលវិទ្យាល័យមួយណាដែរបានផ្តល់សញ្ញាប័ត្របណ្ឌិតដល់លោកនោះ ? ឬមួយក៏គ្រាន់តែជាសញ្ញាប័ត្របណ្ឌិតសេះហោះទេ ? លោករៀនបានខ្ពង់ខ្ពស់ ប៉ុន្តែលោកគ្មានសីលធម៌ គុណធម៌នៅក្នុងខ្លួនបន្តិចសោះ ដែលប្រការនេះធ្វើឲ្យលោកមិនខុសពីក្មេងអន្ធពាល ពាលាអាវ៉ាសែនោះទេ។ លោកគួរតែទៅចូលរៀនសាលាម្តងទៀតទៅ ទើបត្រូវ ហើយទៅដើររកទិញសៀវភៅសុជីវធម៌ សីលធម៌ និងសៀវភៅសិទ្ធិមនុស្សមកមើលឡើងវិញ ! លោកមានសញ្ញប័ត្របណ្ឌិតសេះហោះ ខាងវិទ្យាសាស្ត្រកុំព្យូទ័រ  ប៉ុន្តែលោកគ្មានចំណេះដឹងខាងទស្សនវិជ្ជា ប្រវត្តិសាស្ត្រ និង នយោបាយ នោះទេ !

ខ្ញុំសោកស្តាយដែលលោកមានចំណេះដឹងខ្ពង់ខ្ពស់ហើយប៉ុន្តែលោកមិនបានយកចំណេះដឹងរបស់លោកទៅប្រើប្រាស់ជួយអប់រំ អភីវឌ្ឍន៍សង្គមខ្មែរតាមរយះចំណេះដឹងដែលលោកមាន។ លោកបែរជារត់ទៅរស់នៅឯបរទេស សំងំយកសុខធ្វើរំភើយដោយមិនខ្វីខ្វល់ខ្វាយពីប្រទេសជាតិរបស់លោកសោះ។ ទើបតែបានទៅរស់នៅស្រុកបារាំងមិនទាន់ដល់មួយឆ្នាំផង លោកហ៊ានស្រែកជំទាល តិះដៀលដល់ស្រុកខ្មែរដែលជាប្រទេសផ្តល់កំណើតដល់ខ្លួនលោកទៅហើយ។ខ្ញុំខំប្រឹងសរសើរលោកពីដំបូងថាលោកជាមនុស្សត្រឹមត្រូវមានសុភវិនិច្ឆ័យល្អតែបែរជាលោកប្រែក្លាយទៅជាមនុស្សភ្លេចធាតុកំណើតដូច្នេះទៅវិញ។ សូមលោកទៅឆ្លុះកញ្ចក់មើលខ្លួនលោកម្តងទៀតឡើងវិញផងថាតើលោកមានប្រភពមកពីណា ហើយមានសញ្ជាតិជាអ្វី ? មិនខ្វះទេលោកកូនខ្មែរស្រករលោក  ស្រករខ្ញុំដែលរៀនបានចេះដឹងខ្ពង់ខ្ពស់ហើយគេសុខចិត្តត្រលប់ទៅប្រទេសខ្មែរ វិញដើម្បីជួយអភិវឌ្ឍន៍សង្គមខ្មែរ ប្រទេសខ្មែរ គេមិនរត់ចោលស្រុកដូចលោកហើយប្រឹងស្រែកជំទាលពីបរទេសមើលងាយប្រទេសខ្លួនឯងនោះទេ។

ឃាតករស៊ីឈ្នួលនិងអាជីពជាអ្នកសំលាប់នេះគ្រាន់តែជាឈ្មោះក្លែងក្លាយដែលខ្ញុំលេងនៅតាមបណ្តាញអ៊ីនធើណែតដើម្បីសប្បាយបំបាត់ការអផ្សុកតែប៉ុណ្ណោះ។ស្បែកមុខពិតរបស់ខ្ញុំជាមនុស្សផ្សេងពីនេះហើយសញ្ញាប័ត្របណ្ឌិតសោះហោះដូចលោក ឈរ ណារ៉ា ឃាតករស៊ីឈ្នួលខ្ញុំអត់មានព្រឺរោមស្អីបន្តិចទេ លោកត្រូវដឹងឲ្យច្បាស់ទៅ ! ឃាតករស៊ីឈ្នួលខ្ញុំមិនដើរសំញ៉ែងបង្ហាញអួតគេ ពីរឿងសញ្ញាប័ត្រ និងចំណេះដឹងដើម្បីឲ្យគេកោតខ្លាច សរសើរខ្លួន នៅកណ្តាលវាលដូចជារូបលោកនោះទេ។

**លើកក្រោយសុំលោកឈប់ផ្ញើសំបុត្រឬជាសារអញ្ជើញខ្ញុំឲ្យចូលលេងក្នុងបណ្តាញសង្គមដែលលោកបង្កើតទៀតទៅ ព្រោះខ្ញុំគ្មានពេលទំនេរទេ ! ហើយម្យ៉ាងទៀតខ្ញុំមិនចូលចិត្តចរិត្តរបស់លោកទេ !**

សង្ឃឹមថាលោក ឈរ ណារ៉ា ហៅដើមត្នោតមួយនឹងបានយល់ពីអ្វីដែលឃាតករស៊ីឈ្នួលខ្ញុំបានពន្យល់ ព្រោះលោកជាបញ្ញវន្តខ្មែរជាន់ខ្ពស់មួយរូប ដែលមានចំណេះដឹងទូលំទូលាយ ខ្ពង់ខ្ពស់ ! ហើយសូមលោករៀនប្រើប្រាស់ខួរក្បាលរបស់លោកខ្លះផង !

គួរពុំគួរសុំលោកអភ័យទោសដល់ឃាតករស៊ីឈ្នួលខ្ញុំផង។

**ពីឃាតករស៊ីឈ្នួល**